សំណុំឱកឃ្មុំ ៣/១ (មករា ២០០២)៖ ៣២-៤១



# ពាក់មួកការពារ

*លោក អ៊ួន សិលា*

នៅពេលព្រឹកព្រលឹមនៅតាមដងផ្លូវឆ្ពោះទៅវ៉ាលយន្តហោះ ដែលជាផ្លូវល្អតែមួយគត់ កាលពីសម័យនោះនៅក្នុងទីក្រុងភ្នំពេញ សមល្មមសម្រាប់បើកបរ ដោយហេតុថាផ្លូវដទៃទៀត នៅក្នុងទីក្រុងសុទ្ធតែជាផ្លូវរលាក់ មានក្រលុតដូចជាផ្លូវនៅតាមជនបទដែរ ។ មានទោចក្រយានជាច្រើនដឹកបំពង់ទឹកត្នោតធ្វើដំណើរតាមបណ្តោយផ្លូវនោះ មានម៉ូតូដែលផលិតនៅក្នុងប្រទេសជប៉ុនជាច្រើន ដែលម្ចាស់យានយន្តទាំងនោះកំពុងបញ្ជាប្រទាក់ក្រឡាគ្នាជាមួយនឹង រថយន្ត តូយ៉ូតា ឡង់គ្រូសឺរ ដែលមានពាក់ផ្លាកលេខ “OI” ហើយនៅមិនឆ្ងាយប៉ុន្មាន គេឃើញមានរថយន្តមែរសីដែស ធុនទំនើបៗ ដែលមានពាក់ផ្លាកលេខនិមិត្តសញ្ញាទង់ ជាតិខ្មែរ ហើយគេសរសេរថា "ខ.ម" នៅលើផ្លាកលេខនោះ ។

ដោយសារតែផ្លូវនោះមានលក្ខណៈរលោងស្អាត ទើបផ្លូវឲ្យអ្នកធ្វើចរាចរណ៍នៅលើផ្លូវនោះ មានល្បឿនលឿនមែនទែន ។ ខ្ញុំបានក្រឡេកមើលនាឡិកា ទើបដឹងថា ម៉ោង ៧:៥៥ នាទីហើយ ។ " អូ! ជិតហួសម៉ោងចូលធ្វើការហើយ!" ខ្ញុំឧទានខ្សឹបៗតែម្នាក់ឯង ។ ដូច្នេះខ្ញុំក៏បង្កើន ល្បឿនម៉ូតូ

ហុងដា ១២៥ ពណ៌សដែលជាកេរ្តិ៍ដំណែលកាលពីជំនាន់អ៊ុនតាក់បោះពួយ លឿនស្លេវដូចព្រួញ ។ អាវរបស់ខ្ញុំត្រូវខ្យល់រលាស់ឮសូរភិបៗ ខ្ញុំដៀងភ្នែកមើលកុងទ័រម៉ូតូរបស់ខ្ញុំឡើងដល់៨០ ។ ខ្ញុំបានវ៉ា រថយន្តតួយ៉ូតាពណ៌ស ហើយវ៉ាម៉ូតូ អាសង់ ឌ្រីម ហើយជិតដល់ផ្លូវខ្វែងពេទ្យលោកសង្ឃ ខ្ញុំឃើញឡានដឹកធុងទឹកមួយដែលមានដឹកធុងទឹក ច្រេះស៊ីបើកកាត់ផ្លូវ ពេលដែលកំពុងបើកឡាននោះត្រូវបង្អង់ល្បឿន ធ្វើឲ្យឡានចង់រអិលថយក្រោយ ឃើញដូច្នេះខ្ញុំក៏បង្កើនល្បឿនដើម្បីវ៉ាហួសឡាននោះ ស្រាប់តែ ប្រាវ!!..!

នេះជាសម្លេងដែកប៉ះទង្គិចគ្នា ដោយព្រោះមានល្បឿនលឿនដូចគ្នានោះ ។ នៅកណ្តាលទ្រូងផ្លូវ គេឃើញមានម៉ូតូពីរកំពុងដេកថើបគ្នាយ៉ាងសុខសាន្ត គឺមួយម៉ាក ហុងដា ១២៥ ពណ៌ស និងមួយទៀតម៉ាក ហុងដា សេដេ ៩០ ពណ៌ខ្មៅ ។

ខ្ញុំធុំក្លិនឈ្មៀម ហើយខ្ញុំក៏ព្យាយាមក្រោកពីកន្លែងដួលនោះ តែក្រោកមិនរួចសោះ ដោយជើងរបស់ខ្ញុំមួយគាបជាប់នឹងម៉ូតូមួយទៀត ។ ខ្ញុំបានបើកមួកការពាររបស់ខ្ញុំ ដើម្បីរកមើលឲ្យឃើញថាតើវាមានរះអ្វីទៅ ខ្ញុំបានមើលឃើញតាមប្រហោងជើងខោរហែករបស់ខ្ញុំ ខ្ញុំមើលឃើញមានបំណាស់ពណ៌សពីរកន្លែងជាប់នៅកំភួនជើងរបស់ខ្ញុំ មិនយូរប៉ុន្មានវាក៏ចាប់ផ្តើមប្តូរពណ៌ក្រហមបន្តិចម្តងៗ ហើយពេលនោះការឈឺចាប់ក៏ចាប់ផ្តើមនៅក្នុងពេលជាមួយគ្នានោះដែរ ។

ខ្ញុំក៏ចាប់ផ្តើមព្យាយាមក្រោកឡើងម្តងទៀត ដោយយកដៃទៅច្រត់លើម៉ូតូខ្មៅដែលនៅដេកជាមួយគ្នានោះ ។ គួរឲ្យសោកស្តាយណាស់ខ្ញុំបានច្រត់ខុសកន្លែង គឺច្រត់លើបំពង់ផ្សែងម៉ូតូនោះ ស្រាប់តែ "អូយ" ខ្ញុំស្រែកដោយភ្ញាក់ ។ នៅក្បែរកន្លែងនោះមាននគរបាលចរាចរណ៍ គាត់ក៏មកជួយលើកខ្ញុំឲ្យក្រោកឈរឡើង ។

ម្ចាស់ម៉ូតូមួយទៀតនោះ គឺជាបុរសដែលអាយុប្រហែលជា ៣០ ឆ្នាំ

មានសម្លៀកបំពាក់ឯកសណ្ឋានយោធា ។ គាត់នោះគ្មានទទួលរងរបួសអ្វីឡើយ ។ គាត់បានស្រែកប្រាប់ទៅឲ្យនគរបាលធ្វើការវាស់វែងកន្លែងគ្រោះថ្នាក់នោះ ដើម្បីឲ្យដឹងថាតើនរណាខុសនរណាត្រូវ និងតើនរណាចេញថ្លៃសងនរណា ។ នៅពេលនោះនគរបាលបានប្រាប់ឲ្យខ្ញុំដើរទៅចិញ្ចើមផ្លូវ ដែលមាននគរបាលពីរបីនាក់កំពុងឈរនៅទីនោះ ។ ខ្ញុំខំប្រឹងឈរទាំងឈឺចាប់នៅលើចិញ្ចើមផ្លូវនោះ ។ គឺមានការពិបាកក្នុងការឈរឲ្យនឹងត្រង់ខ្លួនណាស់ ព្រោះជើងរបស់ខ្ញុំម្ខាងនោះមានរបួស ដែលធ្វើឲ្យខ្ញុំឈឺចាប់យ៉ាងខ្លាំង ដូច្នេះខ្ញុំត្រូវដើរប៉ាក់ខ្ញើចៗទៅកន្លែងដែលនគរបាលបង្ហាញខ្ញុំឲ្យដើរទៅ ។ ខ្ញុំឈរនៅទីនោះទាំងបែកញើសជោគអាវដោយព្រោះតែមានការឈឺចាប់ខ្លាំងពេក ។

ខ្ញុំធ្វើជាខំសម្លឹងរកមើលម៉ូតូរបស់ខ្ញុំ ក្រែងមានខូចខាត នៅត្រង់ណាមួយ ដើម្បីបន្លប់ការឈឺចាប់របស់ខ្ញុំ ។ ដៃសំរាប់ចាប់អំប្រិយ៉ាវៀចហើយនិងធុងសាំងមានស្នាមឆ្កូចបន្តិច ។ បុរសម្នាក់ទៀតក៏ខំសង្កេតរកមើលការខូចខាតនៅលើម៉ូតូរបស់គាត់ដែរ ។ "របស់ខ្ញីគេផង" គាត់រអ៊ូ "មិនមែនរបស់ខ្ញុំឯណា" ។ ចង្កៀងមុខរបស់ម៉ូតូគាត់នោះ មានស្នាមឆ្កូតយ៉ាងខ្លាំង ។

នគរបាលម្នាក់និយាយថា៖ "លោកឯងទាំងពីរ ព្យាយាមដោះស្រាយគ្នាទៅ ។ តែបើមិនអាចដោះស្រាយបានទេចាំខ្ញុំជួយប្រាប់ថា អ្នកណាខុសអ្នកណាត្រូវ ... តែដំបូងព្យាយាមសម្រុះសម្រួលគ្នាទៅ" នគរបាលនោះបែរមករកខ្ញុំហើយសួរថា៖ "លោកឯងទៅពីខាងណា មកពីខាងណា?"

ខ្ញុំឆ្លើយថា៖ "ខ្ញុំជិះតាមផ្លូវធំ ពីផ្ទះទៅកន្លែងធ្វើការ"

គាត់ក៏បែរទៅសួរបុរសម្នាក់ទៀត "ចុះលោកខាងនេះទៅឯណាមកពីណា?" បុរសនោះបាននិយាយប្រាប់ពីកន្លែងផ្ទះរបស់គាត់រស់នៅដែលចេញពីតំបន់ត្រឡោកបែក ហើយគាត់ធ្វើដំណើរឆ្ពោះទៅកន្លែងធ្វើ

ការរបស់គាត់នៅត្រង់មុំជិតមន្ទីរពេទ្យព្រះសីហនុ (ពេទ្យរុស្ស៊ី) ។ ដោយសារតែឡានដឹកទឹកនោះឯង ដែលបាំងធ្វើឲ្យយើងទាំងពីរនាក់មិនអាចមើលគ្នាឃើញ ទើបធ្វើឲ្យយើងបុកគ្នាតែម្តង ។

បុរសនោះនៅតែរអ៊ូ "របស់ខ្ញីគេផង ៗ.." ខ្ញុំហាក់ដូចជាខឹងបន្តិចដោយព្រោះហួសម៉ោងចូលធ្វើការ ហើយរបួសរបស់ខ្ញុំចាប់ផ្តើមឈឺខ្លោកៗ "តើលោកឯងចង់ឲ្យខ្ញុំសងចំពោះការខូចខាតម៉ូតូរបស់លោកឯងឬ?" គាត់នោះនៅស្ងៀម ហើយខ្ញុំក៏ប្រមូលសេចក្តីក្លាហានរបស់ខ្ញុំទាំងអស់មកហើយក៏សួរទៅនគរបាលថា៖ "តើខ្ញុំត្រូវសងគាត់ឬគាត់ត្រូវសងខ្ញុំ?"

នគរបាលឆ្លើយថា៖ "តើចង់ឲ្យខ្ញុំប្រាប់ថាអ្នកណាត្រូវសងនរណាមែនឬ ដោយយោងតាមច្បាប់ចរាចរណ៍នោះ?"

ភ្លាមនោះបុរសម្នាក់នោះបាននិយាយថា៖ "តោះទៅ! ខ្ញុំមិនចង់ឲ្យនរណាសងនរណាទៀតឡើយ" ខ្ញុំក៏លានគរបាលហើយបន្តដំណើរទៅកាន់កន្លែងធ្វើការរបស់ខ្ញុំ ។

ទៅដល់កន្លែងធ្វើការនៅម៉ោងប្រហែល៨:៣០ ។ "ជើងរបស់អ្នកឯងកើតអ្វីហ្នឹង?" ម៉ាសា ដែលជាជនជាតិហ្វីលីពីនស្នាក់នៅក្នុងការិយាល័យរបស់អង្គការ វ៉ាយវ៉ាម ដើម្បីរៀនភាសាមុនពេលចុះទៅធ្វើការនៅតាមខេត្ត។ "ខ្ញុំឆ្លើយទាំងសើចបណ្តើរថា ខ្ញុំបិះទៅស្ថានសួគ៌មុនម៉ាសាឯង" នាងក៏ញញឹមហើយក៏រត់ឡើងទៅក្នុងបន្ទប់របស់នាង ដើម្បីយកប្រដាប់ប្រដាមករុំរបួសឲ្យខ្ញុំ ។ រុំបណ្តើរ ឲ្យដំបូន្មានខ្ញុំបណ្តើរថា៖ "ពេលជិះម៉ូតូ ចូរប្រុងប្រយ័ត្នបន្តិចទៅ"

ខ្ញុំបានប្រកែកថា៖ "ខ្ញុំនឹងប្រុងប្រយ័ត្ន ចុះបើគេមិនប្រយ័ត្ននោះ តើមានអ្វីប្លែកនោះ?"

តើមានមនុស្សប៉ុន្មាននាក់ដែលអារម្មណ៍ដូចខ្ញុំដែរនោះ?

ចំណុចដ៏រំភើបចិត្តអស្ចារ្យជាងគេបំផុតនៅក្នុងទីក្រុងភ្នំពេញនោះ

គឺការធ្វើចរាចរណ៍ ។ គ្រោះថ្នាក់កំពុងតែរង់ចាំទទួលនៅចំពោះមុខយើង ។ យើងមិនដឹងថាតើនៅពេលណាទៅ យើងនឹងជួបប្រទះគ្រោះថ្នាក់នោះ ហើយមិនដឹងថាតើវាធ្ងន់ឬឈឺចាប់ប៉ុណ្ណាទេ នៅពេលដែលវាប៉ះចំយើងនោះ។ តើយើងត្រូវការឲ្យមាននរណាម្នាក់មកជួយយើងទេ នៅពេលដែលយើងជួបប្រទះគ្រោះថ្នាក់នោះ? មែន ប្រាកដណាស់ហើយ! នៅក្នុងគ្រោះថ្នាក់របស់ខ្ញុំនោះ បើខ្ញុំមិនបានពាក់មួកទេនោះ ខ្ញុំប្រហែលជាមានរបួសក្បាលធ្ងន់ធ្ងរមែនទែន ។ បើនគរបាលមិនមកជួយលើកខ្ញុំទេនោះ ខ្ញុំប្រហែលជាមិនអាចក្រោករួចឡើយ ព្រោះជើងរបស់ខ្ញុំទាំងពីរត្រូវកង់ម៉ូតូគៀបជាប់ ។ សូម្បីតែប្រធានរបស់ខ្ញុំក៏និយាយដែរថា បើកូនប្រុសរបស់គាត់ណាថាន់បានពាក់មួកការពារ នៅពេលដែលគាត់ជួបប្រទះគ្រោះថ្នាក់ នោះប្រហែលជាមិនមានគ្រោះថ្នាក់ធ្ងន់ធ្ងរនៅលើមុខរបស់គាត់ ដែលជា ហេតុធ្វើឲ្យគាត់ត្រូវជិះយន្តហោះទៅក្រុងបាងកក ដើម្បីធ្វើការវះកាត់នោះឡើយ ។ លោកអ្នកឃើញទេថា មួកការពារនោះវាសំខាន់ប៉ុណ្ណាទៅ! យើងត្រូវការមួកការពារ! ដំបូន្មានរបស់ម៉ាសាថាឲ្យប្រុងប្រយ័ត្ន និងច្បាប់ចរាចរណ៍នោះមិនគ្រប់គ្រាន់ឡើយ ។ ខ្ញុំត្រូវការមានមនុស្សណាម្នាក់មកជួយខ្ញុំឲ្យក្រោកឡើងបាន ។ តើមានមនុស្សចំនួនប៉ុន្មាននាក់កំពុងតែមានអារម្មណ៍ខ្លួនកំពុងជាប់នៅក្នុងបញ្ហាដែលមិនអាចដោះខ្លួនរួចនោះ ដូចដែរខ្ញុំជាប់នៅក្នុងប្រឡោះកង់ម៉ូតូទាំងពីរនោះ?

បន្ទាប់ពីម៉ាសាបានរុំរបួសខ្ញុំរួចហើយនោះ ខ្ញុំចាប់ផ្តើមប្តូរការព្រួយចិត្តរបស់ខ្ញុំពីមុខរបួសមកព្រួយចិត្តអំពីរឿងខោរបស់ខ្ញុំទៅវិញ ។ កាលនោះខ្ញុំមានតែខោពីរសម្រាប់ប៉ុណ្ណោះ តែឥឡូវនេះខោមួយត្រូវខូចខាត ដោយសារគ្រោះថ្នាក់ទៅហើយ ។ ខ្ញុំជាជនមាតុភូមិនិវត្តន៍ថ្មីៗមកពីជំរំជនភៀសខ្លួននៅក្នុងប្រទេសថៃ ។ ដូចលោកអ្នកដឹងស្រាប់ហើយក្នុងនាមជាជនមាតុភូមិនិវត្តន៍ម្នាក់មកពីជំរំថ្មីៗនោះ មិនសូវមានលុយកាក់ប៉ុន្មានទេ ។

ខ្ញុំរអ៊ូម្នាក់ឯងតិចៗថា៖ "ហ៊ី! ប៉ះប៉ុនលែងកើតហើយ" ។

លុះថ្ងៃបន្ទាប់មកទៀត ខ្ញុំបានមកធ្វើការដូចធម្មតា ។ស្រាប់តែ! ខ្ញុំឃើញមានខោថ្មីមួយដេកធ្វើព្រងើយនៅលើតុធ្វើការរបស់ខ្ញុំ ។ នៅថ្ងៃដែលខ្ញុំមានគ្រោះថ្នាក់នោះ នៅចំថ្ងៃដែលភីលីពប្រធានរបស់ខ្ញុំ គាត់វិលពីស្ទឹងត្រែងមក ហើយគាត់បានទៅផ្សារ ពេលគាត់មកពីផ្សារវិញខ្ញុំឃើញខោថ្មីនោះនៅលើតុរបស់ខ្ញុំ ពេលនោះខ្ញុំអរស្ទើរហោះ គឺអរខ្លាំងមែនទែន ដោយខ្ញុំកំពុងតែព្រួយចិត្តរឿងខោមានតែមួយនោះ តែឥឡូវនេះខ្ញុំមានខោពីរដូចដើមវិញហើយ ។

តើលោកអ្នកដឹងទេថាមានម្នាក់ ដែលរង់ចាំជួយយើងគ្រប់ពេលគ្រប់វេលាទាំងអស់? ម្នាក់នោះមិនគ្រាន់តែជួយផ្នែកសេចក្តីត្រូវការខាងឯវិញ្ញាណរបស់លោកអ្នកប៉ុណ្ណោះទេ តែជួយទាំងសេចក្តីត្រូវការផ្នែករូបកាយរបស់លោកអ្នកទៀតផង ។ ម្នាក់នោះជាអ្នកជួយផ្គត់ផ្គង់យើង និងជាគង្វាលដ៏ប្រសើរ ដែលជួយទាញយើងចេញពីលោកីយ៍ដែលប្រកបទៅដោយអំពើបាប ។ ម្នាក់នោះមាននាមថា ព្រះយេស៊ូ!

សូមឲ្យខ្ញុំជំរាបរឿងមួយទៀតដល់លោកអ្នក ។ អំពើបាបធ្វើឲ្យខ្ញុំនឹកឃើញទៅដល់ឡានជាប់ផុក ។ នៅពេលល្ងាចមួយនោះ នៅពេលដែលខ្ញុំធ្វើការងារចែកចាយសំបុត្រស្នាមខ្លះៗ និងធ្វើការកំប៉ិកកំប៉ុកខ្លះ នៅត្រង់ម្តុំបឹងទំពុន ដែលនៅជិតផ្ទះម្តាយមីងរបស់ខ្ញុំ ។ នៅមុខព្រះវិហារទំនប់ទឹកមានផ្លូវលំមួយ ។ មុនទៅមួយថ្ងៃមានភ្លៀងធ្លាក់យ៉ាងខ្លាំង អ្នកនៅតាមដងផ្លូវនោះគេបានចូកដីមកលុបត្រង់កន្លែងដែលមានផុក ដើម្បីជួសជុលផ្លូវនោះដោយប្រើវិធីនេះឯង ។ ផ្លូវនោះមើលទៅដូចជាមិនមានអ្វីគួរបារម្ភទេ តែនៅពីស្រទាប់ក្រោមនោះខ្ញុំដឹងថាមានផុកនៅឡើយ ។ នៅពេលដែលខ្ញុំឃើញភ្លាមខ្ញុំដឹងថាប្រហែលជាអាចមានបញ្ហា ពេលដែលខ្ញុំបើកឡានពីលើផ្លូវនោះ ។ ប៉ុន្តែដោយខ្ញុំដឹងថាឡានដែលខ្ញុំកំពុងបើកនេះ គឺជាឡាន

ដែលមានកាឡេមុខក្រោយ ដូច្នេះខ្ញុំចង់សាកលមើល ។ ភ្លាមនោះកង់មុខម្ខាងក៏រអិលធ្លាក់ចូលនៅក្នុងប្រឡាយតូចមួយដែលនៅអមផ្លូវនោះ ។ ខ្ញុំក៏ព្យាយាមបង្កើនល្បឿនយ៉ាងខ្លាំង តែខ្ញុំមិនអាចឡើងរួចពីប្រឡាយនោះឡើយ ដូច្នេះខ្ញុំចាប់ផ្ដើមដាក់លេខកាពីតាស់ តែនៅតែមិនអាចធ្វើខ្លួនរួចទៀត ។

មុនដំបូងខ្ញុំសប្បាយចិត្ត ហើយនិយាយថា៖ "អឺយ៉ា! តែប៉ុណ្ណោះ មានឱកាសប្រើលេខកាពីតាស់ហើយអីតើ!" ប៉ុន្តែនៅពេលដែលខ្ញុំខំប្រឹងព្យាយាមធ្វើឲ្យរួចពីផុកកាន់តែខ្លាំង ឡានកាន់តែលិចកាន់តែខ្លាំង ព្រះសូរិយាកាន់ទន់ទាបហៀបអស្តង្គតនាទិសបស្ចិមទៅហើយ ។ ស្បៃអន្ធការក៏ចាប់ផ្ដើមគ្របដណ្ដប់ផែនប្រថពីបន្តិចម្តងៗ ។ សេចក្ដីរំភើបចិត្តរបស់ខ្ញុំដែលថាសប្បាយក្នុងការប្រើលេខកាពិតាស់នោះ ក៏រសាយបន្តិចម្ដងៗទៅតាមរស្មីព្រះសូរិយាទៅដែរ ។ បេះដូងរបស់ខ្ញុំចាប់ផ្ដើម លោតយ៉ាងខ្លាំងដោយបង្ហាញពីសេចក្ដីទុក្ខព្រួយទៅវិញ ។ ខ្ញុំគិតថាបបូរមាត់របស់ខ្ញុំចាប់ផ្ដើមប្រែស្វាយលាយឡំនឹងតំណក់ហូរស្រោចចិញ្ចើម ដង្ហើមប្តូរទៅជាញាប់បង្គាប់ឲ្យខ្ញុំរកគំនិតថ្មី ។ ពេលនោះខ្ញុំគិតចង់ប្រើត្រើយដើម្បីទាញឡាននោះ តែនៅជិតនោះគ្មានដើមឈើដែលអាចផ្ដក់បានឡើយ ។

នៅក្នុងទីធ្លាខាងមុខព្រះវិហារទំនប់ទឹកមានយុវជនមួយក្រុមកំពុងលេងបាល់ទះ ។ ខ្ញុំដាច់ចិត្តស្រែកហៅឲ្យគេជួយ យុវជនទាំងនោះក៏នាំគ្នាមកជួយរុញឡានឲ្យរំកិលផុតពីកន្លែងដែលមានផុកស្អិតនោះរហូតដល់ខ្ញុំអាចប្រើទាញខ្សែត្រើយយកទៅផ្ដក់ដើមដូងមួយដើមដែលនៅជិតនោះ ។ ទីបំផុតខ្ញុំអាចធ្វើរួចចេញពីផុកស្អិតនោះ មិនមែនដោយសារតែខ្ញុំជាអ្នកប៉ិនប្រសប់ក្នុងការបើកបរនោះឡើយ ឬដោយសារតែខ្ញុំចេះច្បាប់ចរាចរណ៍នោះឡើយ ឬក៏ដោយសារតែខ្ញុំបើកឡានដែលមានកាឡេមុខក្រោយនោះដែរ ។ ខ្ញុំអាចធ្វើរួចចេញពីផុកនោះ គឺដោយសារតែមានជំនួយពីប្រភពខាងក្រៅខ្លួនឯងប៉ុណ្ណោះ គឺមិនមែនគ្រាន់តែខ្លួនទីពឹងខ្លួននោះឡើយ ។

ចំពោះអំពើបាបក៏ដូចគ្នានេះដែរ ។ គឺវាមិនអាស្រ័យលើការអប់រំដ៏ល្អដែលអ្នកមាននោះទេ ឬក៏ដោយសារតែអំពើល្អរបស់អ្នកដែលអ្នកខំធ្វើនោះឡើយ ឬក៏លោកអ្នកខំព្យាយាមគោរពតាមក្បួនច្បាប់ទាំងឡាយឲ្យបានល្អប៉ុណ្ណានោះឡើយ ។ ការទាំងអស់នេះមិនអាចជួយលោកអ្នកឲ្យរួចពីអំពើបាបបានឡើយ ។ ហេតុអ្វី? ពីព្រោះយើងបានកើតមកដោយជាប់មាននិស្ស័យបាបជាប់មកជាមួយ និងបានកើតមកក្នុងពូជមនុស្សដែលធ្លាក់ក្នុងអំពើបាបយ៉ាងធ្ងន់ធ្ងរ! អំពើបាបបានចូលមកក្នុងពិភពដ៏ល្អប្រពៃរបស់ព្រះជាម្ចាស់យើងនេះ តាមរយៈការមិនស្តាប់បង្គាប់ព្រះរបស់អ័ដាម ។ អ្វីដែលយើងត្រូវការនោះគឺជាកម្លាំងពីខាងក្រៅ ដើម្បីជួយទាញយើងឲ្យរួចពីភក់ស្អិត... ឬជួយទាញឲ្យរួចពីការគ្រោះថ្នាក់ដោយម៉ូតូសង្កត់លើ ក្នុងករណីដែលខ្ញុំបានជួបប្រទះនៅពេលដែលខ្ញុំជួបប្រទះគ្រោះថ្នាក់ ។

កម្លាំងមកពីខាងក្រៅនោះគឺជាព្រះជាម្ចាស់ ។ គឺមានន័យថាព្រះអង្គមិនមែនមាននិស្ស័យលក្ខណៈដូចមនុស្សនោះឡើយ (ព្រះអង្គគ្មានបាបសោះ) ។ ព្រះអង្គបរិសុទ្ធ និងសុចរិត! ព្រះអង្គអាចជួយសង្គ្រោះយើងដោយសារព្រះគុណរបស់ព្រះអង្គ ។

មនុស្សជាច្រើនតែងនិយាយថា បើថ្នាំពូកែនោះមិនចាំបាច់ផ្សាយឃោសនាទេ គង់តែប្រសិទ្ធិភាពរបស់ថ្នាំនោះគេនឹងបានដឹងដោយខ្លួនឯង នៅថ្ងៃណាមួយជាក់ជាមិនខាន ។ តើពិតដូច្នេះមែនឬ? ខ្ញុំមិនបានគិតដូច្នោះទេ ។ មនុស្សយើងធម្មតាតែងតែធ្វើមិនដឹងមិនឮ ចំពោះរបស់អ្វីមួយដែលជួយសង្គ្រោះដល់ជីវិតរបស់ខ្លួន ។ ខ្ញុំបានសង្កេតឃើញការផ្សាយពាណិជ្ជកម្មនៅតាមទូរទស្សន៍ កម្រឃើញមានគេផ្សាយលើកកំពស់របស់ដែលមានប្រយោជន៍នោះឡើយ ដូចជាផ្សាយពីគុណប្រយោជន៍នៃការប្រើមួកការពារនៅពេលជិះម៉ូតូ (ដែលជារបស់ជួយសង្គ្រោះជីវិតមនុស្ស) ប៉ុន្តែរបស់ដែលនាំឲ្យអន្តរាយដល់ជីវិតវិញនោះខ្ញុំឃើញគេផ្សាយច្រើនដូចជា បារី

ស្រាបៀរ និងស្រាផ្សេងៗ (ដែលអាចបំផ្លាញដល់សុខភាពមនុស្ស) ។ គេធ្វើម៉េចឲ្យគេដឹងថាមួកការពារមានប្រយោជន៍នោះ លុះត្រាលោកអ្នកប្រាប់គេទើបគេដឹងបាន?

ចំពោះរឿងព្រះយេស៊ូក៏មិនខុសគ្នាដែរ ធ្វើម៉េចឲ្យគេស្គាល់ព្រះអង្គបានដរាបណាមានមនុស្សទៅប្រាប់គេឲ្យបានឮអំពីរឿងនោះ ។ "ហើយគ្រប់គ្នាគឺអស់អ្នកណាដែលអំពាវនាវដល់ព្រះនាមព្រះអម្ចាស់ នោះនឹងបានសង្គ្រោះ ដូច្នេះបើគេមិនជឿ ធ្វើដូចម្តេចឲ្យគេអំពាវនាវដល់ព្រះបាន ហើយបើគេមិនបានឮនិយាយ នោះធ្វើដូចម្តេចឲ្យគេជឿដល់ព្រះបាន ហើយធ្វើដូចម្តេចឲ្យគេឮនិយាយបាន បើគ្មានអ្នកណាប្រាប់សោះ មួយទៀតធ្វើដូចម្តេចឲ្យមានអ្នកណាប្រាប់បាន លើកតែមានអ្នកណាចាត់ឲ្យគេទៅ?..."[១] ។

បើសិនលោកអ្នកមិនដែលឮអ្នកណាប្រាប់លោកអ្នក ពីមុនមកទេនោះ ឥឡូវនេះខ្ញុំសូមប្រាប់លោកអ្នកគឺថា៖ លោកអ្នកត្រូវការព្រះយេស៊ូ! ហើយនិងសូមពាក់មួកសឹកនៃសេចក្តីសង្គ្រោះ ។

បើគ្រាន់តែពាក់មួកការពារនៅពេលដែលលោកអ្នកជិះម៉ូតូនោះ គឺមិនគ្រប់គ្រាន់ឡើយ ប៉ុន្តែលោកអ្នកត្រូវការមួកសឹកនៃសេចក្តីសង្គ្រោះរបស់ព្រះជាម្ចាស់ផងដែរ ។ បើគ្រាន់តែស្តាប់តាមសេចក្តីបង្រៀនរបស់មនុស្សដែលម្នាក់ដែលមានបទពិសោធន៍នោះ គឺមិនគ្រប់គ្រាន់ឡើយ គឺមិនអាចជួយលោកអ្នកបានឡើយ ។ ដូចគ្នានេះដែរគ្មាននរណាម្នាក់អាចរត់គេចចេញពីអំពើបាបបានដោយសារខំគោរពតាមក្រឹត្យវិន័យរបស់សាសនាផ្សេងៗនោះបានឡើយ ។ អំពើបាបប្រៀបបានដូចជាលោកអ្នកជាប់គៀបនៅចន្លោះម៉ូតូទាំងពីរដែលដួលពីលើគ្នាដូច្នេះដែរ...

---

*១ រ៉ូម ១០:១៣-១៥*

## សរុបសេចក្តី

- មួកការពារនោះសំខាន់ណាស់នៅពេលដែលលោកអ្នកជិះម៉ូតូ នៅក្នុងចរាចរណ៍ដ៏ណែនណាន់តាន់តាប់នៅក្នុងទីក្រុងភ្នំពេញនោះ ។
- លោកអ្នកត្រូវការមួកសឹកនៃសេចក្តីសង្គ្រោះ ដើម្បីការពារគំនិតរបស់លោកអ្នកឲ្យរួចពីការវាយលុករបស់អារក្សសាតាំង ។
- នៅពេលដែលគៀបជាប់នៅចន្លោះម៉ូតូទាំងពីរនោះ លោកអ្នកត្រូវការមានអ្នកណាម្នាក់មកជួយ និងពេលដែលឡានលោកអ្នកជាប់ផុងក្នុងភក់ស្អិតនោះលោកអ្នកត្រូវការឲ្យមានគេមកជួយទាញចេញពីភក់ស្អិតនោះ ។
- យើងត្រូវការព្រះយេស៊ូ (ដូចជានគរបាល ឬ ដូចជាអ្នកលេងបាលទះ) ដើម្បីជួយយើងឲ្យរួចពីអំពើបាប ។

HONEYCOMB 3/1 (January 2002): 42–46



# Wearing A Helmet

*UON Seila*

At dawn the broad boulevard toward the airport is the only road in Phnom Penh that seems fit for driving, since the other city streets are as bumpy and potholed as the country lanes. Battered bicycles balance bamboo bottles brimming with palm tree juice, and tired Japanese motor scooters weave among the gleaming white Toyota Landcruisers marked "OI" and the Mercedes sedans bearing the Cambodian flag on their number plates.

The road looked smooth that morning, so everyone sped along. I glanced at my watch—seven fifty-five. "Oh! It's already late for work!" I murmured. So I gunned my white Honda 125—formerly owned by UNTAC. My shirt flapped furiously in the breeze. A glance at my speedometer told me I was doing 80 km/h. I overtook a white Toyota Landcruiser and a red Honda Dream II 100, and then at the road junction I saw a truck with a rusty water tank. While it was crossing the road it seemed like it was going to slip back, so I tried to speed up to overtake that truck and then—***CRASH***!!!

Two speeding metal machines had slammed together. Now on the pavement lay two motorbikes—my white Honda 125 and a black Honda CD 90.

I smelled something burning and tried to get up, but could not because one of my legs was stuck in the wheel of the other motorbike. I pulled up my visor to see what was burning. Through a hole in my

trousers leg I spied two white patches on my calf that were gradually turning red, and felt pain at the same time.

Again I tried to get up by pushing my hand against one part of the black motorbike. Unfortunately I chose the wrong part—the exhaust pipe. "OUCH!" I cried. A nearby policeman came and helped me stand.

The owner of the other motorbike was a man in his thirties wearing an army uniform. He was uninjured. He asked the policeman to measure the accident site to determine who was right and who was wrong, in order to know who would have to pay whom. By then the officer told me to walk to the roadside where some other policemen were standing. I limped in torment to the roadside. It was difficult to balance because one leg hurt so badly, so I dragged myself to where he instructed me to go. I was sweating profusely from the pain.

I inspected my motorbike for damage in order to distract my mind from the pain. The hand clutch was twisted and the fuel reservoir scratched. The other man also inspected his bike. "It was borrowed," he said. "It is not mine." His headlight was scratched very badly.

One policeman said, "You two must try to come to an agreement. But if you cannot, I will help determine which of you is right and which is wrong. But first try to compromise between the two of you." He turned to me. "Where were you coming from?" he asked.

"I was riding on the main road from home to work," I answered.

He turned to the other man. He said he was riding from his house in red-light district toward his office near Sihanouk Hospital. Because of the truck we could not see each other and therefore collided.

The man kept nagging, "It was borrowed." I grew annoyed because I was already late for work and my wound still throbbed. "Do you want me to pay for the damage of your motorbike?" I asked. He said nothing. I mustered all my courage and asked the policeman, "Do I need to pay him or does he need to pay me?"

The officer replied, "Do you want me to tell you which one has to pay according to the traffic laws?"

Then the other man said, "Let's just go. I don't want anyone to pay." Then I said good-bye to the policeman.

Around 8:30 I arrived at YWAM office where I worked. "What happened to your trouser leg?" inquired Marcia, a Filipino who was staying in YWAM office for language study before starting work in the province. I replied with a little chuckle, "Oh, this morning I nearly went to heaven before you!" She smiled, went upstairs to retrieve her personal medical kit, and dressed my leg. "Be careful when you are riding on your motorbike!" she scolded.

"I'll be careful, but even if I am it doesn't make any difference," I protested.

How many people feel the same as I do?

One of the most fascinating aspects of Phnom Penh is the traffic. Accidents are just waiting to happen. We are never sure when we will get into one, and how serious or painful it will be when we do. Do we need somebody to help us in those circumstances? Yes, we certainly do! In my accident, had I not been wearing a helmet I might have seriously injured my head. And if a policeman had not helped me get up I might not have been able to because my leg was caught in a wheel. Even my boss said that if his son Nathan had been wearing a helmet he would not have so seriously injured his face that he had to fly to Bangkok for surgery. You see the importance of a helmet! We need helmets! Marcia's instruction, "Be careful!" and the traffic laws were not enough. I needed a *person* to help me get up. How many people, I wonder, feel caught in the middle of a problem, just as I was caught in that wheel?

After Marcia dressed my wound I switched my worrying to my trousers. I owned only two pairs of trousers, but now one pair was destroyed by the accident. I was a new returnee from a refugee camp in Thailand, so finances were so slim. "They cannot be mended," I murmured to myself.

The next day I came to work as usual. On my desk lay a new pair of trousers! The day of my accident Philip returned from Stung Treng and bought me a new pair. I was very happy that I could have two pairs of trousers.

Do you know of Someone who is always waiting to help you?

He is not only concerned with your spiritual need, but your physical need as well. He is our provider and good policeman who can pull you out of the snare of this sinful world. His name is Jesus!

Let me tell another story. Sin reminds me of a car stuck in the mud. One evening I went on errands in Boeung Tompon where my aunt lives. In front of the Tumnop Toeuk Church runs a small dirt road. Rain had fallen the day before. People often shovel dirt on top of the mud to try to fix a road after such rains. The road then *looks* good, but underneath traction remains treacherous. When I saw this newly-"repaired" road, I knew that it probably still had problems. But, equipped as I was with a four-wheel-drive vehicle, I determined to try it anyway. Soon one of the front wheels slipped into a small ditch beside the road. I tried to accelerate but I could not get out of the ditch so I shifted into 4WD. Still it would not move out.

At first I was happy and said to myself, "I'm glad to have a chance to use my 4WD!" But as I worked on and on at trying to free the truck, the sun gradually sank in the west. It was growing darker and darker. My excitement at using the 4WD turned to worry. My heart pounded quickly deep down in my chest. My lips turned blue and sweat flowed across my eyebrows. I wanted to use the winch, but there was no tree nearby to which I could hook.

In the church compound I saw a group of young people playing volleyball. I called to them for help, so they came and pushed me out of the sticky mud until I was close enough to hook the winch cable to a nearby coconut tree. Finally I escaped the mud—not because of how skillful a driver I was, or how well I knew the traffic laws, or how well-built a 4WD truck I drove. I only broke free because of help from an outside source.

It was the same with sin. It does not matter how well educated you are, or how many good deeds you do, or what set of rules you try to keep. These will never set you free from sin. Why? Because you were born with a sinful nature and in a fallen human race! Sin entered God's beautiful world through the disobedience of Adam. What we need is an outside force to pull us out of the sticky mud . . . or out of the two fallen motorbikes as in my accident.

The outside force is God. He is not of the same nature as man.

He is holy and righteous! He can save us through His grace.

Many people say that if a medicine is effective there is no need to advertise it—somehow its value will become known all by itself. Is that true? I don't think so. People often ignore things that could save their lives. I observe that television commercials rarely promote useful things such as helmets (which can save people's lives), but rather lethal items such as cigarettes, beer, and wine (which can destroy them). How can people know that helmets are important unless you tell them?

It is the same with Jesus. People will not know unless they hear about him. "'Everyone who calls on the name of the Lord will be saved.' How, then, can they call on the one they have not believed in? And how can they believe in the one of whom they have not heard? And how can they hear without someone preaching to them? And how can preach unless they are sent?"[1]

If you have never heard someone tell you before, I am telling you now: You NEED Jesus! And WEAR YOUR HELMET of salvation.

It is not enough to just wear a helmet when you ride your motorcycle, but you need God's HELMET OF SALVATION as well. Mere instruction from an experienced person cannot help you. Similarly, one cannot escape sin by obeying the law of any religions. It is the same as if you were in the middle of two motorcycles....

## Conclusion

- A helmet is very important when you ride your motorbike through bad traffic like that in Phnom Penh.
- You need the helmet of salvation to protect your mind from being attacked.
- When caught in two motorbikes you need someone to help you; and when your truck is stuck in the mud, you need someone to help pull you out.
- We need Jesus (like the policeman or the volleyball players) to help us out of sin.

---

[1]Rom 10:13–15.